# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

### គោរពជូន
### លោកជំទាវ អាន្លី សុខ អាន ព្រមទាំងក្រុមគ្រួសារ

**លោកជំទាវ ព្រមទាំងក្រុមគ្រួសារ ជាទីគោរពរាប់អាន !**

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ យើងខ្ញុំមានសេចក្តីក្រៀមក្រំនិងរន្ធត់ចិត្តយ៉ាងក្រៃលែងចំពោះការទទួលមរណភាពរបស់ **សម្តេចចិបុលបញ្ញា សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃ ០៣ រោច ខែ ផល្គុន ឆ្នាំ វក អដ្ឋស័ក ពុទ្ធសករាជ ២៥៦០ ត្រូវនឹងថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៧ វេលាម៉ោង ១៨:៣២ នាទី នៅមន្ទីរពេទ្យទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ដោយរោគាពាធ ក្នុងជន្មាយុ ៦៦ឆ្នាំ ។

មរណភាពរបស់ **សម្តេចចិបុលបញ្ញា** គឺជាការបាត់បង់ឥស្សរជន និងវីរជនដ៏ឆ្នើមមួយរូប ដែលបានបូជាអស់កម្លាំងកាយ ប្រាជ្ញា និងស្មារតី ចូលរួមរក្សាបាននូវសុខសន្តិភាព ឯកភាពជាតិ អធិបតេយ្យ បូរណភាពទឹកដី និងអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនជឿនលឿន ព្រមទាំងលើកកម្ពស់កិត្យានុភាពជាតិខ្មែរ ទាំងលើឆាកជាតិ និងអន្តរជាតិ ជាពិសេស ក្នុងភារកិច្ចថែរក្សា អភិរក្ស និងលើកកម្ពស់វប្បធម៌ជាតិ និងបេតិកភណ្ឌពិភពលោក។ ខ្ញុំជឿជាក់ថា ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបនឹងចងចាំជានិច្ចនៅក្នុងក្រអៅបេះដូង នូវពលិកម្ម គុណបំណាច់ដ៏ធំធេង និងស្នាដៃដ៏វិសេសវិសាលដែល **សម្តេចចិបុលបញ្ញា** បានបន្សល់ទុកសម្រាប់ជាតិមាតុភូមិទាំងមូល ដែលនេះជាកេរ្តិ៍វីរភាពដ៏ថ្លៃថ្លាបំផុតសម្រាប់កុលបុត្រ កុលធីតាខ្មែរជំនាន់ក្រោយយកគម្រប់តាម ។

ក្នុងក្តីវិយោគដ៏សែនក្រៀមក្រំស្ទើររកទីបំផុតគ្មាននេះ យើងខ្ញុំសូមសម្តែងនូវសមានទុក្ខសោកស្តាយអាឡោះអាល័យយ៉ាងក្រៃលែង និងសូមចូលរួមរំលែកទុក្ខជាមួយលោកជំទាវ និងក្រុមគ្រួសារទាំងអស់ ដែលបានបាត់បង់ **សម្តេចចិបុលបញ្ញា** ដែលជា ស្វាមី បិតា បិតាក្មេក ជីតា ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់ ។

ស្ថិតក្នុងពេលវេលាដ៏សែនក្រៀមក្រំនេះ យើងខ្ញុំសូមលំអោនកាយឧទ្ទិសបួងសួងដល់គ្រប់វត្ថុស័ក្តិសិទ្ធិក្នុងលោក តាមជួយបីបាច់ថែរក្សាដួងវិញ្ញាណក្ខន្ធរបស់ **សម្តេចចិបុលបញ្ញា** បានទៅកាន់សុគតិភពជានិច្ចនិរន្តរ៍តរៀងទៅ ។

សូម លោកជំទាវ បុត្រា បុត្រី និងក្រុមគ្រួសារទាំងអស់ ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំនេះ ពីយើងខ្ញុំទាំងអស់គ្នា

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
No 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨